ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ៤២១..... ដនស/អសភ

រាជធានីភ្នំពេញ ,ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១២

# សេចក្ដីណែនាំ
## ស្ដីពី
## ការចុះបញ្ជីក្បាលដីទំនាស់ ដែលត្រូវបានដោះស្រាយចប់ជាស្ថាពររួចហើយ

អនុលោមតាមច្បាប់ភូមិបាលឆ្នាំ២០០១ ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ត្រូវបានចាត់ទុកថា មានតម្លៃត្រឹមត្រូវតាមច្បាប់ និងមានអានុភាពច្បាស់លាស់ ។ ចំពោះក្បាលដីទំនាស់ ពុំអាចធ្វើការចុះបញ្ជី និងចេញប័ណ្ណជូនបានឡើយ ប៉ុន្តែតាមការអនុវត្តជាក់ស្ដែងក្នុងរយៈកាលកន្លងមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកត់សំគាល់ឃើញថា មានក្បាលដីទំនាស់មួយចំនួន ត្រូវបានបញ្ចូលទិន្នន័យក្នុងកំព្យូទ័រ និងសៀវភៅគោលបញ្ជីដីធ្លី ដូចក្បាលដីគ្មានទំនាស់ដែរ ដោយគ្រាន់តែមូលដ្ឋានទិន្នន័យក្នុងកំព្យូទ័រ មានបញ្ជាក់ថា ជាក្បាលដីទំនាស់ ហើយពុំត្រូវបានបោះពុម្ពវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យប្រើប្រាស់ ។ ស្ថានភាពទំនាស់លើក្បាលដីនីមួយៗ មានលក្ខណៈខុសៗគ្នា ជាអាទិ៍ ក្បាលដីខ្លះ មានទំនាស់អំពីព្រំដី ក្បាលដីខ្លះមានទំនាស់អំពីសិទ្ធិលើក្បាលដី ហើយទំនាស់ខ្លះ កើតមានក្នុងពេលបំពេញការងារវាល (កំណត់ព្រំ វាស់វែង និងបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី) ដែលទិន្នន័យក្បាលដី មិនទាន់ត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ និងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ និងទំនាស់ខ្លះទៀត កើតមាននៅពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដែលទិន្នន័យក្បាលដីត្រូវបានបញ្ចូលក្នុងកំព្យូទ័រ និងបញ្ជីឈ្មោះម្ចាស់ដីរួច ហើយនៅពេលដោះស្រាយទំនាស់ចប់ជាស្ថាពរ អាចត្រូវបានតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយទំនាស់ សម្រេច ឬភាគីទំនាស់ព្រមព្រៀង កែប្រែអត្តសញ្ញាណក្បាលដី ឬអត្តសញ្ញាណម្ចាស់ដី ឬសិទ្ធិលើក្បាលដីខុសពីទិន្នន័យដែលបានបញ្ចូលក្នុងកំព្យូទ័រ ឬដែលបានកត់ត្រាចូលក្នុងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លីរួចហើយនោះ ។

ដូចនេះ ដើម្បីអនុវត្តបានត្រឹមត្រូវតាមស្មារតីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយដើម្បីដោះស្រាយបញ្ហាដូចបានលើកឡើងខាងលើនេះ និងចៀសវាងមានការភ័ន្តច្រឡំក្នុងការផ្ដល់ពត៌មានដីធ្លីដល់សាធារណជន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ដែលអនុវត្តការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដូចខាងក្រោម :

១. រាល់ក្បាលដីទំនាស់ដែលមិនអាចដោះស្រាយបាន នៅពេលបញ្ចប់ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ទីរត្រូវបញ្ឈប់លែងឱ្យបញ្ចូលទិន្នន័យក្បាលដីទំនាស់នោះ ចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី តទៅទៀត ។

២. ចំពោះក្បាលដីទំនាស់ ដែលបានបញ្ចូលទិន្នន័យក្នុងកំព្យូទ័រ និងសៀវភៅគោលបញ្ជីដីធ្លី ក្នុងពេលកន្លងរួចហើយ មន្ទីរត្រូវសរសេរនៅលើសន្លឹកសៀវភៅគោលបញ្ជីដីធ្លី នៃក្បាលដីទំនាស់នោះ ត្រង់ខ្ទង់សេចក្ដីផ្សេងៗ ថា " ក្បាលដីទំនាស់ " ជាទឹកក្រហម រួចបោះត្រាលេខាធិការ ជាទឹកខៀវ ហើយចុះកាលបរិច្ឆេទ និងចុះហត្ថលេខាបំព្រួញ ជាទឹកខ្មៅ ឬខៀវ (គំរូលេខ០១) ។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660, Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet Com. Kh